# ខ្ញុំចង់ជឿដែរ ប៉ុន្តែ....

ឆ្លើយតបសំណួរ ដែលទាក់ទងនឹង

ប្រពៃណីគ្រួសារ និងអាកប្បកិរិយារបស់គ្រីស្ទបរិស័ទ

# ខ្ញុំចង់ជឿដែរ

# ប៉ុន្តែ...

## ឆ្លើយតបសំណួរ ដែលទាក់ទងនឹង

*ប្រពៃណីគ្រួសារ និង*
*អាកប្បកិរិយារបស់គ្រីស្ទបរិស័ទ*

EDITORS: Chia Poh Fang,
Amos Khan, Khan Hui Neon,
Leslie Koh
DESIGN & LAYOUT: Felix Xu
COVER & CONTENT PHOTOS:
Shutterstock.com

រក្សាសិទ្ធិគ្រប់យ៉ាងដោយ នំម៉ាណាប្រចាំថ្ងៃ
© 2020 (website: khmer-odb.org)
បទគម្ពីរជាភាសាខ្មែរដកស្រង់ចេញពីព្រះគម្ពីរបរិសុទ្ធ ភាសាខ្មែរ បកប្រែចាស់ ឆ្នាំ១៩៥៤ ដោយការអនុញ្ញាតិ និងរក្សាសិទ្ធិដោយសមាគមន៍ព្រះគម្ពីរសកល (បានដកស្រង់ ដោយរក្សាអក្ខរាវិរុទ្ធដើម)។

បន្ទាប់ពីលោកម៉ៃឃែល(Michael) បានឮដំណឹងល្អរបស់ព្រះយេស៊ូវ និងបានជជែកអំពីដំណឹងល្អនោះ ជាមួយមិត្តភក្តិមួយចំនួន ដែលជាគ្រីស្ទបរិស័ទ គាត់ក៏បានសម្រេចចិត្តជឿថា ព្រះទ្រង់បានចាត់ព្រះរាជបុត្រាទ្រង់ ព្រះនាមយេស៊ូវ ឲ្យមកសុគតដើម្បីលោះបាបមនុស្សជាតិ ហើយមនុស្សអាចទទួលការអត់ទោសបាប បើសិនជាពួកគេទទួលជឿព្រះយេស៊ូវ។ គាត់ថែមទាំងបានចាប់ផ្តើមទៅព្រះវិហារ រៀងរាល់ថ្ងៃអាទិត្យ ដើម្បីរៀនសូត្របន្ថែមអំពីជំនឿគ្រីស្ទបរិស័ទ។ ទោះជាយ៉ាងណាក៏ដោយ គាត់មិនទាន់ធ្វើការសម្រេចចិត្ត ដើរតាមព្រះយេស៊ូវនៅឡើយទេ។ គាត់មិនមានការបដិសេធន៍ណាមួយ ចំពោះជំនឿគ្រីស្ទបរិស័ទនោះទេ ប៉ុន្តែឪពុកម្តាយគាត់មិនព្រមឲ្យគាត់ទទួលជឿព្រះឡើយ។

ពួកគេជាអ្នកកាន់តាមសាសនា ដែលជាប្រពៃណីរបស់ជនជាតិពួកគេ ដូចនេះ ពួកគេគិតថា បើម៉ៃឃែលក្លាយជាគ្រីស្ទាន នោះគាត់នឹងបោះបង់វប្បធម៌របស់ពួកគេ ដើម្បីទទួលយកជំនឿរបស់ "ប្រទេសលោកខាងលិច"។ ក្នុងនាមជាកូនច្បង គាត់មានកាតព្វកិច្ចបន្តប្រពៃណីយរបស់គ្រួសារគាត់ ដែលរាប់បញ្ចូលការធ្វើពិធីបុណ្យ និងការអនុវត្តន៍ ដែលពួកគេបានចាត់ទុកជាផ្នែកមួយដ៏សំខាន់ ក្នុងវប្បធម៌ និងប្រពៃណីរបស់ពួកគេ។ ម៉ៃឃែលមានការព្រួយបារម្ភថា បើសិនជាគាត់ទទួលជឿព្រះយេស៊ូវជាព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះ គាត់នឹងនាំឲ្យមានការបែកបាក់ក្នុងគ្រួសារ និងធ្វើឲ្យបាត់ភាពសុខដុម។ ឪពុកម្តាយគាត់នឹងពិបាកចិត្តជាងគេ ហើយអាចកាត់កាល់គាត់ ដោយចោទថា គាត់មិនសមជាកូនរបស់

ការប្រឈមមុខដាក់ការប្រឆាំង ពីក្រុមគ្រួសារ ជាការលំបាកដែលកើតមានជាធម្មតា។



ពួកគាត់ ឬជាកូនអកតញ្ញូជាដើម។

ពួកគេធ្លាប់ប្រាប់គាត់ថា “បើកូនចូលសាសនាយេស៊ូវ កូននឹងក្លាយជាមនុស្សក្បត់ជាតិសាសន៍ និងវប្បធម៌ខ្លួនឯង”។

ពាក្យសម្ដីនេះបានដក់ជាប់ក្នុងចិត្តម៉ែយលរៀងរាល់ពេលគាត់ទៅចូលរួមកម្មវិធីថ្វាយបង្គំព្រះ នៅព្រះវិហារ។ តើគាត់អាចធ្វើដូចនេះ ចំពោះឪពុកម្ដាយរបស់គាត់ឬទេ? តើគាត់នឹងធ្វើឲ្យពួកគាត់ឈឺចាប់ ដោយសារគាត់ក្លាយជាគ្រីស្ទបរិស័ទឬ?

ហ៊ួជេ(Huijie) ក៏មានការពិបាក នៅក្នុងការទទួលជឿព្រះយេស៊ូវផងដែរ។ នាងមានចិត្តចង់ទទួលជឿថា ព្រះជាម្ចាស់ គឺជាព្រះអាទិករ ហើយព្រះយេស៊ូវ គឺជាព្រះរាជបុត្រាព្រះអង្គ។ ប៉ុន្តែ នាងមានការសង្ស័យបន្តិចបន្តួច អំពីជំនឿរបស់គ្រីស្ទបរិស័ទ។ បើសិនជាព្រះទ្រង់ជាព្រះដ៏ល្អ ដូចគេនិយាយមែន តើហេតុអ្វីគ្រីស្ទានខ្លះ ជាមនុស្សអាក្រក់?

មិត្តរួមការងាររបស់ហ៊ួជេ គឺជាគ្រីស្ទបរិស័ទ តែពួកគេហាក់ដូចជាមនុស្សអាក្រក់បំផុត ដែលគាត់ធ្លាប់ធ្វើការជាមួយ។ តើហេតុអ្វីពួកគេប្រកាសថា ខ្លួនជាអ្នកជឿព្រះយេស៊ូវ ខណៈពេលដែលពួកគេមានអាកប្បកិរិយាអាក្រក់យ៉ាងខ្លាំង? នាងប្រាប់មិត្តភក្តិរបស់នាងថា “ខ្ញុំមើលមិនឃើញតម្លៃ នៃការរស់នៅជាគ្រីស្ទបរិស័ទទាល់តែសោះ។ តើគ្រីស្ទបរិស័ទគួរតែរស់នៅជាមនុស្ស ដែលល្អជាងគេមែនទេ? តើការលាក់ពុតរបស់ពួកគេ បានឆ្លុះបញ្ចាំង អំពីជំនឿរបស់ពួកគេ យ៉ាងដូចម្ដេចខ្លះ?”

**តើសំណួរ និងចម្ងល់ទាំងនេះធ្លាប់ធ្វើឲ្យអ្នកមានការស្ទាក់ស្ទើរ នៅក្នុងការសម្រេចចិត្តដើរតាមព្រះយេស៊ូវឬ?**

មនុស្សជាច្រើនបានសួរសំណួរដូចនេះ គឺមិនខុសពីម៉ែយល និងហ៊ួជេឡើយ ហើយចម្ងល់ទាំងនេះមិនមានអ្វីខុសឆ្គងទេ? ការប្រឈមមុខដាក់ការប្រឆាំង ពីក្រុមគ្រួសារ ជាការលំបាកដែលកើតមានជាធម្មតា ជាពិសេស នៅប្រទេស នៅទ្វីបអាស៊ី ហើយការព្យាយាមបកស្រាយចម្ងល់ និងសំណួរដែលអ្នក ឬក្រុមគ្រួសារអ្នកមាន អំពីជំនឿគ្រីស្ទបរិស័ទក៏មិនមែនជាការងាយស្រួលដែរ។ យើងខ្ញុំមានការសប្បាយចិត្ត ដែលបញ្ហាទាំងនេះមិនបានរារាំងអ្នក មិនឲ្យពិចារណា អំពីជំនឿរបស់គ្រីស្ទបរិស័ទ ហើយយើងខ្ញុំសូមលើកទឹកចិត្តអ្នកឲ្យបន្តសួរសំណួរទាំងនេះទៀត។

ក្នុងកូនសៀវភៅនេះ យើងខ្ញុំសូមលើកយកសំណួរមួយចំនួន និងការព្រួយបារម្ភ ដែលទាក់ទងនឹងការក្លាយជាគ្រីស្ទបរិស័ទ។ អ្នកប្រហែលជាមិនយល់ស្រប ចំពោះចម្លើយ និងការបកស្រាយខ្លះ ក្នុងសៀវភៅនេះ ប៉ុន្តែ យើងខ្ញុំសង្ឃឹមថា អ្នកនឹងផ្លាស់ប្ដូរទស្សនៈរបស់អ្នក បន្ទាប់ពីបានពិចារណា អំពីបញ្ហានេះ។

## ការប្រឈមមុខដាក់សំណួរពិបាកៗ

### ១.តើខ្ញុំត្រូវតែលះបង់វប្បធម៌ និងប្រពៃណីរបស់ខ្ញុំ ដើម្បីក្លាយជាគ្រីស្ទបរិស័ទឬ?

**ការក្លាយជាគ្រីស្ទបរិស័ទ គឺរាប់បញ្ចូលការលះបង់ជីវិត “ចាស់” ដែលមិនស្តាប់បង្គាប់ព្រះ។** គឺមានន័យថា ងាកបែកចេញពីអំពើបាប ហើយព្យាយាមរស់នៅ តាមស្តង់ដាររបស់ព្រះ។ ប៉ុន្តែ មនុស្សជាច្រើនមានការបារម្ភថា ពួកគេនឹងបោះបង់វប្បធម៌ និងប្រពៃណីយរបស់ខ្លួនផងដែរ។ ពួកគេក៏បានចោទជាសំណួរថា តើជីវិតចាស់របស់ខ្ញុំ រាប់បញ្ចូល គោលតម្លៃ ការអនុវត្ត និងរបៀបនៃការរស់នៅ ដែលគេបានបង្រៀនខ្ញុំឲ្យគោរព និងដើរតាមតាំងពីក្មេងមកឬ? តើមានន័យថា ខ្ញុំមិនអាចអរសប្បាយនឹងថ្ងៃបុណ្យប្រពៃណីជាតិ និងចូលរួមការអនុវត្តតាមវប្បធម៌ ជាមួយក្រុមគ្រួសារ?

នេះជាបញ្ហាប្រឈមធំមួយ នៅក្នុងវប្បធម៌ និងជាតិសាសន៍មួយចំនួន។ ពេលដែលការអនុវត្តន៍ និងរបៀបនៃការរស់នៅរបស់យើង ហាក់ដូចជាខុសប្លែកពីការអនុវត្តន៍ និងរបៀបនៃការរស់នៅរបស់ “គ្រីស្ទបរិស័ទ” ដែលឃើញមាន នៅក្នុងសង្គមលោកខាងលិច នោះយើងប្រហែលជាមានអារម្មណ៍ថា យើងកំពុងតែទទួលរងសម្ពាធ ឲ្យបោះបង់ចោលជាតិសាសន៍ ឬកេរដំណែលវប្បធម៌របស់យើង ពេលណាយើងចង់ក្លាយជាគ្រីស្ទបរិស័ទ គឺមិនខុសពីម៉ែឃលឡើយ។



**ការដើរតាមព្រះយេស៊ូវ មិនមែនជាការបោះបង់ចោលជាតិសាសន៍ និងកេរដំណែលវប្បធម៌របស់យើងនោះឡើយ។**

ទោះជាយ៉ាងណាក៏ដោយ ព្រះទ្រង់មិនបានឲ្យយើងសម្រេចចិត្តធ្វើដូចនេះទេ។ ការដើរតាមព្រះយេស៊ូវ មិនមែនជាការបោះបង់ចោលជាតិសាសន៍ និងកេរដំណែលវប្បធម៌របស់យើងនោះឡើយ។ តាមពិត ព្រះជាអ្នកបង្កើតឲ្យមានជាតិសាសន៍ខុសៗគ្នា ហើយក៏បានប្រទានឲ្យយើងមានសហគមន៍ និងវប្បធម៌ដែលមានលក្ខណៈពិសេសរៀងៗខ្លួន។ ជាការពិតណាស់ ព្រះអង្គមិនបានហាមឃាត់យើង មិនឲ្យគោរព និងឲ្យតម្លៃ ចំពោះវប្បធម៌ និងប្រពៃណីរបស់យើងនោះឡើយ នៅត្រង់ចំណុចណា ដែលមិនប្រាសចាកគោលជំនឿរបស់គ្រីស្ទបរិស័ទ។

ហើយការគោរពនេះ នឹងបានបង្ហាញឲ្យក្រុមគ្រួសារដឹងថា ការក្លាយជាគ្រីស្ទបរិស័ទ មិនបានកាត់ផ្ដាច់ខ្លួនយើងចេញពីពួកគេនោះទេ។

## ២. តើខ្ញុំអាចបន្តប្រពៃណី ដែលខ្ញុំបានកាន់តាម តាំងពីក្មេងមកឬទេ?

**ព្រះជាម្ចាស់មិនបានប្រាប់អ្នក ឲ្យធ្វើការសម្រេចចិត្តជ្រើសរើស រវាងព្រះអង្គ និងវប្បធម៌ប្រពៃណីរបស់អ្នកឡើយ** ប៉ុន្តែ មានផ្នែកខ្លះ ក្នុងវប្បធម៌ប្រពៃណីយនោះ អាចធ្វើឲ្យប៉ះពាល់មកលើជំនឿរបស់អ្នក។ មានការអនុវត្តន៍ និងពិធីបុណ្យខ្លះ បានរាប់បញ្ចូលការថ្វាយបង្គំរូបចម្លាក់ ឬធ្វើអ្វីដែលខុសនឹងព្រះហឫទ័យព្រះ។ ពេលណាអ្នកកាន់តែមានភាពស្និទ្ធស្នាល ជាមួយព្រះ អ្នកចាំបាច់ត្រូវស្គាល់ ហើយឈប់អនុវត្តតាម ឬធ្វើពិធីបុណ្យ ដែលប្រាសចាកព្រះរាជបញ្ញារបស់ព្រះអង្គ ដែលបង្គាប់ឲ្យដើរតាម និងស្ដាប់បង្គាប់ព្រះអង្គ។ ជាការពិតណាស់ នេះមិនមែនជាការងាយឡើយ។ យើងចាំបាច់ត្រូវសិក្សាព្រះគម្ពីរ និងអធិស្ឋានដល់ព្រះ ទូលសូមប្រាជ្ញា ដើម្បីឲ្យយើងអាចដឹងច្បាស់ថា មានទំនៀមទំលាប់ណាខ្លះ ដែលយើងអាចបន្តកាន់តាម ហើយទំនៀមទំលាប់ណាខ្លះដែលយើងមិនត្រូវកាន់តាម។ យើងចាំបាច់ត្រូវស្វែងរកចម្លើយក្នុងព្រះគម្ពីរប៊ីប គឺមិនត្រូវបែងចែកវប្បធម៌ណាជារបស់អាស៊ី ឬអ៊ឺរ៉ុបនោះទេ។

## ៣. តើជំនឿគ្រីស្ទបរិស័ទ គឺជាជំនឿ “របស់អឺរ៉ុប”មែនទេ?

**មានប្រពៃណីយជាច្រើនរបស់គ្រីស្ទបរិស័ទ ដែលហាក់ដូចជាមានដើមកំណើត ក្នុងសង្គមលោកខាងលិច** ប៉ុន្តែ យើងចាំបាច់ត្រូវចាំថា ជំនឿគ្រីស្ទបរិស័ទមានប្រភពមកពីតំបន់មជ្ឈិមបូព៌ា។ ព្រះគម្ពីរត្រូវបាននិពន្ធឡើង ក្នុងតំបន់មជ្ឈិមបូព៌ា ហើយព្រះយេស៊ូវក៏បានប្រសូត្រ និងចម្រើនវ័យធំឡើង ក្នុងតំបន់នេះឯង។ ជំនឿគ្រីស្ទបរិស័ទមានភាពជិតស្និទ្ធកាន់តែខ្លាំង នឹងសង្គមអឺរ៉ុប គឺដោយសារជំនឿគ្រីស្ទបរិស័ទមានការផុសផុលខ្លាំងនៅទ្វីបអឺរ៉ុប នៅសម័យក្រោយមកទៀត។



▶ យើងចាំបាច់ត្រូវស្វែងរកចម្លើយក្នុងព្រះគម្ពីរប៊ីប គឺមិនត្រូវបែងចែកវប្បធម៌ណាជារបស់អាស៊ី ឬអឺរ៉ុបនោះទេ។

## ៤. ចុះបើសិនជាក្រុមគ្រួសារខ្ញុំបដិសេធមិនឲ្យខ្ញុំក្លាយជាគ្រីស្ទបរិស័ទ?

**ការសម្រេចចិត្តដើរតាមព្រះយេស៊ូវគ្រីស្ទ គឺជាការសម្រេចចិត្តផ្ទាល់ខ្លួន** ប៉ុន្តែ គ្រួសាររបស់អ្នក អាចមានឥទ្ធិពលខ្លាំង មកលើជីវិត និងការលូតលាស់របស់អ្នកក្នុងនាមជាគ្រីស្ទាន។ ពួកគេអាចរារាំងជំនឿដែលអ្នកទើបតែមាននេះ ព្រោះពួកគេមិនចង់ឲ្យអ្នកធ្វើខុសនឹងប្រពៃណីរបស់គ្រួសារ វប្បធម៌ និងសាសនារបស់ពួកគេ ហើយមានការបារម្ភថា ការសម្រេចចិត្តរបស់អ្នកនឹងមានផលប៉ះពាល់មកលើការរួបរួម និងភាពសុខដុមរបស់គ្រួសារអ្នក។

តើអ្នកអាចប្រឈមមុខដាក់ការបដិសេធន៍ដូចនេះ ដោយរបៀណា? វិធីទីមួយ យើងអាចប្រាប់ពួកគេថា ការក្លាយជាគ្រីស្ទាន គឺមិនមែនជាការបដិសេធមរតកវប្បធម៌របស់អ្នកឡើយ ហើយអ្នកនៅតែអាចគោរព និងធ្វើតាមប្រពៃណីណាដែលមិនប្រាសចាកជំនឿរបស់គ្រីស្ទបរិស័ទ។ ពេលណាអ្នកមានឱកាស អ្នកអាចជួយពន្យល់ពួកគេ ឲ្យលែងមានការយល់ច្រឡំ ឬការយល់ខុស អំពីជំនឿគ្រីស្ទបរិស័ទ។ វិធីមួយទៀត យើងអាចបង្ហាញពួកគេថា ព្រះកំពុងតែកែប្រែជីវិតអ្នកឲ្យល្អជាងមុន ហើយជំនឿរបស់អ្នកកំពុងតែបង្រៀនអ្នក ឲ្យស្រឡាញ់ និងយកចិត្តទុកដាក់ចំពោះសមាជិកគ្រួសារ តាមរបៀបដែលជ្រាលជ្រៅជាងមុខ។ បើអ្នករស់នៅ តាមផ្លូវរបស់ព្រះ នោះការប្រព្រឹត្ត ពាក្យសម្ដី និងអាកប្បកិរិយារបស់អ្នកអាចកែប្រែទស្សនៈដែលពួកគេមានចំពោះជំនឿគ្រីស្ទបរិស័ទ។

ព្រះជាម្ចាស់ជ្រាប អំពីបញ្ហាប្រឈមដែលអ្នកជួបប្រទះ។ បើសិនជាអ្នកពិបាកនិយាយប្រាប់គ្រួសារអ្នកថា អ្នកបានសម្រេចចិត្តក្លាយជាគ្រីស្ទបរិស័ទ នោះសូម



**▶ ការក្លាយជាគ្រីស្ទាន គឺមិនមែនជាការបដិសេធមរតកវប្បធម៌របស់អ្នកឡើយ។**

អធិស្ឋាន សូមប្រាជ្ញា និងការដឹកនាំមកពីព្រះ។ ចូរទូលសូមព្រះអង្គ ឲ្យបង្ហាញឲ្យអ្នកដឹងថា ពេលណាជាពេលដ៏ត្រឹមត្រូវ ដែលអ្នកអាចប្រាប់គ្រួសារអ្នកឲ្យដឹង ហើយសូមព្រះអង្គឲ្យបង្ហាញ ឲ្យអ្នកដឹងពីរបៀបនិយាយទៅកាន់ពួកគេដោយប្រុងប្រយ័ត្ន និងដោយការគោរព។ អ្នកក៏អាចសុំយោបលពីបងប្អូនរួមជំនឿ ហើយសុំឲ្យពួកគេអធិស្ឋានឲ្យអ្នក។

## ៥. ហេតុអ្វីគ្រីស្ទបរិស័ទខ្លះ មានអាកប្បកិរិយាអាក្រក់ម្ល៉េះ?

**អ្នកប្រហែលជាមានសំណួរដូចហ្នឹងថា :** បើសិនជំនឿរបស់គ្រីស្ទបរិស័ទ ធ្វើឲ្យមនុស្សល្អជាងមុខ ហេតុអ្វីគ្រីស្ទបរិស័ទខ្លះមានអាកប្បកិរិយាអាក្រក់ម្ល៉េះ? តើអាកប្បកិរិយាអាក្រក់នោះ បានឆ្លុះបញ្ចាំងអំពីជំនឿរបស់គ្រីស្ទបរិស័ទយ៉ាងណាខ្លះ? គ្រួសាររបស់អ្នកប្រឆាំងមិនឲ្យអ្នកជឿព្រះ អាចប្រហែលមកពីពួកគេធ្លាប់មានបទពិសោធន៍អាក្រក់ ជាមួយគ្រីស្ទាន។

អ្នកអាចស្វែងយល់អំពីបញ្ហានេះ ដូចតទៅ។ ពាក្យ “គ្រីស្ទាន ឬគ្រីស្ទបរិស័ទ” ច្រើនតែត្រូវបានគេប្រើជាផ្លូវការ ដើម្បីហៅមនុស្សមួយក្រុម ដែលដើរតាមព្រះ ហើយព្យាយាមស្ដាប់បង្គាប់ទ្រង់ ហើយផ្លាស់ប្រែឲ្យមានអាកប្បកិរិយា និងលក្ខណៈកាន់តែដូចព្រះយេស៊ូវ ដែលជាព្រះរាជបុត្រាព្រះអង្គ។ ព្រះទ្រង់ជ្រាបថា អ្នកដើរតាមព្រះអង្គពិតប្រាកដ មានអាកប្បកិរិយា និងលក្ខណៈសម្បត្តិដូចម្ដេច។

ពេលណាមនុស្សម្នាក់ក្លាយជាគ្រីស្ទបរិស័ទ គឺមិនមានន័យថា គាត់នឹងឈប់ប្រព្រឹត្តអំពើបាបនោះឡើយ។ បន្ទាប់ពីយើងបានងាកបែរទៅរកព្រះហើយ យើងមិនក្លាយជាមនុស្សល្អឥតខ្ចោះភ្លាមៗដែរ។ ដរាបណាយើងនៅមានជីវិត



ក្នុងពិភពលោកពេញដោយអំពើបាប យើងនឹងនៅតែជួបការល្បួងឲ្យធ្វើអំពើបាប ហើយយើងនឹងនៅតែជំពប់ដួល និងធ្វើខុស ពេញមួយជីវិត។ ព្រះទ្រង់បានសង្គ្រោះយើង ឲ្យរួចពីលទ្ធផលនៃអំពើបាប(ការដាច់ចេញពីព្រះ) និងរួចផុតពីអំណាចដែលវាមានមកលើយើង ប៉ុន្តែ យើងនៅតែជួបការលំបាក ដោយសារវត្តមានរបស់វាក្នុងជីវិតយើង។ ហេតុនេះហើយបានជា ពេលខ្លះ យើងឃើញគ្រីស្ទបរិស័ទមួយចំនួន មានអាកប្បកិរិយាមិនល្អ។

ទោះជាយ៉ាងណាក៏ដោយ យើងអាចដឹងច្បាស់ថា ព្រះជាម្ចាស់កំពុងតែធ្វើការ ក្នុងជីវិតយើងម្នាក់ៗ ដើម្បីធ្វើឲ្យយើងកាន់តែមានចរិយាសម្បត្តិ និងអាកប្បកិរិយា ដូចព្រះយេស៊ូវ។ ការផ្លាស់ប្រែក្នុងជីវិតយើង គឺមិនទាន់ចប់នៅឡើយទេ។ យូរៗទៅ ពេលណាយើងដើរតាមព្រះយេស៊ូវ ដោយការស្ដាប់បង្គាប់ នោះយើងនឹងរៀនផ្គាប់ចិត្តព្រះ ដោយពាក្យសម្ដី ការប្រព្រឹត្ត និងអាកប្បកិរិយារបស់យើង។

ម្យ៉ាងទៀត យើងក៏ត្រូវដឹងផងដែរថា យើងពិបាកនឹងធ្វើការវិនិច្ឆ័យ មកលើអាកប្បកិរិយារបស់អ្នកដទៃ ដោយមិនដឹងថា មានរឿងអ្វីខ្លះកំពុងតែកើតឡើង ក្នុងជីវិតពួកគេ។ យើងមិនដឹងថា ពួកគេបានឆ្លងកាត់ ឬកំពុងឆ្លងកាត់បញ្ហាអ្វីខ្លះទេ ហើយបញ្ហាទាំងនោះមានផលប៉ះពាល់យ៉ាងណាខ្លះ មកលើអាកប្បកិរិយារបស់ពួកគេ។ ពុំនោះទេ ពួកគេប្រហែលជាមានការផ្លាស់ប្ដូរច្រើនណាស់ បើធៀបនឹងកាលពីមុន។ ហេតុនេះហើយ ព្រះគម្ពីរប៊ីបបានក្រើនរំឭកយើង ឲ្យផ្ដោតទៅលើការធ្វើដំណើរខាងវិញ្ញាណរបស់ខ្លួនយើង គឺមិនត្រូវវាស់ស្ទង់ជីវិតអ្នកដទៃ ផ្អែកទៅលើស្ដង់ដាររបស់ពួកគេនោះឡើយ។

ហើយអ្នកអាចមានការកម្សាន្តចិត្ត ដោយដឹងថា គ្រីស្ទបរិស័ទមិនល្អឥតខ្ចោះ គឺមិនមានន័យថា ព្រះទ្រង់គ្មានអំណាចកែប្រែពួកគេនោះឡើយ។ មានមនុស្សជាច្រើនដែលបានផ្លាស់ប្រែជាវិជ្ជមាន បន្ទាប់ពីពួកគេងាកមករកព្រះ ដែលនេះជាគំរូដ៏ល្អ។ ការនេះបានបង្ហាញថា ព្រះជាម្ចាស់កំពុងតែធ្វើការ ក្នុងជីវិតគ្រីស្ទបរិស័ទទាំងអស់។ វាជាដំណើរការដ៏វែងឆ្ងាយ អស់មួយជីវិត។



▶ ព្រះគម្ពីរប៊ីបបានក្រើនរំឭកយើង ឲ្យផ្ដោតទៅលើការធ្វើដំណើរខាងវិញ្ញាណរបស់ខ្លួនយើង។

# ការស្វែងរកជំនួយពីព្រះ

**ជាការពិតណាស់ បញ្ហាមួយចំនួន ដែលយើងបានលើកយកមកនិយាយក្នុងសៀវភៅនេះ គឺមិនងាយស្រួលដោះស្រាយទេ។** អ្នកប្រហែលជាមានបញ្ហាដែលពិបាកជាងបញ្ហារបស់លោកម៉ៃយល ឬមានសំណួរដែលពិបាកឆ្លើយ ជាងសំណួររបស់ហ្ស៊ីជេ។ ប៉ុន្តែ កុំបាក់ទឹកចិត្តឡើយ ព្រះទ្រង់ជ្រាប។ ព្រះអង្គមានព្រះទ័យរីករាយពេលដែលមនុស្សងាកបែរមករកព្រះអង្គ។ បើអ្នកបន្តស្វែងយល់បំណងព្រះទ័យព្រះ នោះព្រះអង្គនឹងប្រទានប្រាជ្ញា និងការដឹកនាំ នៅក្នុងការដោះស្រាយបញ្ហាទាំងនេះ នៅពេលណាមួយ។ បញ្ហាខ្លះអាចត្រូវការពេលវេលាមួយរយៈ ដើម្បីដោះស្រាយ។

ទោះជាយ៉ាងណាក៏ដោយ អ្នកមិនចាំបាច់ត្រូវរកឲ្យបានចម្លើយ សម្រាប់សំណួរ និងការសង្ស័យទាំងអស់ដែលអ្នកមាន មុននឹងអ្នកសម្រេចចិត្តទទួលជឿព្រះអង្គជាព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះនោះឡើយ។ វាមិនអីទេ ដែលអ្នកនៅមានសំណួរ ពេលដែលអ្នកចូលមកចំពោះព្រះ។ ព្រះអង្គជ្រាបអំពីការលំបាក ការសង្ស័យ និងសំណួររបស់អ្នក ហើយព្រះអង្គនឹងសប្បាយព្រះទ័យ ពេលដែលអ្នកនៅតែបោះជំហានទៅមុខ ដោយជំនឿទាំងនៅមានសំណួរ និងការសង្ស័យ។ ពេលណាយើងទទួលជឿព្រះយេស៊ូវ ព្រះអង្គនឹងចាត់ព្រះវិញ្ញាណព្រះអង្គ ឲ្យគង់នៅក្នុងចិត្តយើង ហើយដឹកនាំយើង នៅក្នុងការធ្វើដំណើរនៃសេចក្ដីជំនឿ។

ព្រះអង្គមានបន្ទូលថា “ខ្ញុំមិនចោលអ្នករាល់គ្នាឲ្យនៅកំព្រាទេ ខ្ញុំនឹងមកឯអ្នករាល់គ្នាវិញ É តែព្រះដ៏ជាជំនួយគឺជាព្រះវិញ្ញាណបរិសុទ្ធ ដែលព្រះវរបិតានឹងចាត់មក ដោយនូវឈ្មោះខ្ញុំ ទ្រង់នឹងបង្រៀនអ្នករាល់គ្នា ពីគ្រប់សេចក្ដីទាំងអស់ ក៏នឹងរំឭកពីគ្រប់ទាំងសេចក្ដី ដែលខ្ញុំបានប្រាប់ដល់អ្នករាល់គ្នាដែរ”(យ៉ូហាន ១៤:១៨,២៦)។ បើអ្នកមានអារម្មណ៍ថាប៉ះពាល់ចិត្ត ពេលដែលអ្នកបានអាន ឬស្ដាប់ការបកស្រាយអំពីព្រះយេស៊ូវ នោះសូមអធិស្ឋានទៅរកព្រះអង្គចុះ។ ចូរនិយាយទៅកាន់ព្រះអង្គ ហើយសូមឲ្យព្រះអង្គបើកបង្ហាញសេចក្ដីពិតដល់អ្នក។ អ្នកអាចជជែកជាមួយគ្រីស្ទបរិស័ទណាម្នាក់ ដែលអាចជួយពន្យល់អ្នក អំពីបញ្ហាទាំងនេះ។ ព្រះទ្រង់នឹងឆ្លើយតប ព្រោះព្រះអង្គស្រឡាញ់អ្នក។ ព្រះអង្គសព្វព្រះទ័យឲ្យអ្នកស្គាល់ព្រះអង្គ ដើម្បីឲ្យអ្នកអាចទទួលសេចក្ដីសង្គ្រោះរបស់ព្រះអង្គ ដែលបានប្រទានមកតាមរយៈព្រះយេស៊ូវ។





▶ បើអ្នកមានអារម្មណ៍ថា អ្នកបានត្រៀមចិត្តដើម្បីដើរតាមព្រះយេស៊ូវ នោះយើងខ្ញុំសូមលើកទឹកចិត្តអ្នកឲ្យធ្វើការសម្រេចចិត្តនៅពេលឥឡូវនេះ។

# ធ្វើការសម្រេចចិត្ត

បើអ្នកបានត្រៀមខ្លួន ដើម្បីដើរតាមព្រះយេស៊ូវហើយ នោះខ្ញុំសូមលើកទឹកចិត្តអ្នក ឲ្យធ្វើការសម្រេចចិត្តនៅពេលឥឡូវនេះ។ ចូរទូលដល់ព្រះថា អ្នកជឿព្រះយេស៊ូវ ដែលជាព្រះរាជបុត្រាព្រះអង្គ ហើយជឿថា ព្រះអង្គសុគតជំនួសអ្នក នៅលើឈើឆ្កាង ហើយបានមានព្រះជន្មរស់ឡើងវិញ ហើយអ្នកបានត្រៀមខ្លួនដើម្បីទទួលជឿព្រះអង្គ ជាព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះហើយ។ ព្រះជាម្ចាស់តែងតែស្តាប់អ្នកជានិច្ច ដូចនេះ អ្វីដែលអ្នកត្រូវធ្វើ គឺត្រូវនិយាយទៅកាន់ទ្រង់ គឺហាក់ដូចជាទ្រង់កំពុងតែនៅពីមុខអ្នក។ បើសិនជាអាច សូមស្វែងរកមិត្តភក្តិជាគ្រីស្ទបរិស័ទ ឲ្យអធិស្ឋានជាមួយអ្នក និងធ្វើជាសាក្សីរបស់អ្នក។ ការក្លាយជាគ្រីស្ទបរិស័ទ គឺមានន័យថា យើងទទួលស្គាល់ និងជឿដូចតទៅ:

- ព្រះជាម្ចាស់បង្កើតយើងមក ឲ្យមាន**ទំនាក់ទំនងនៃសេចក្តីស្រឡាញ់** ជាមួយព្រះអង្គ
- តែយើងម្នាក់ៗ**បានទាស់ប្រឆាំងនឹង**ព្រះអង្គ ដោយរស់នៅ តាមស្តង់ដាររបស់យើង ហើយបានបដិសេធអំណាចរបស់ព្រះអង្គ
- ទង្វើរនេះគឺជា**អំពើបាប** ហើយទោសនៃអំពើបាប គឺជា**សេចក្តីស្លាប់**
- ប៉ុន្តែ ព្រះទ្រង់ប្រទាន**ដំណោះស្រាយ** មកយើងរាល់គ្នា ដោយចាត់**ព្រះរាជបុត្រាព្រះអង្គ ព្រះយេស៊ូវគ្រីស្ទ ឲ្យសុគតជំនួសយើង។**

- ព្រះយេស៊ូវបានសុគត តែបីថ្ងៃក្រោយមក **ព្រះអង្គមានព្រះជន្មរស់ឡើងវិញ** ដោយបង្ហាញថា ព្រះជាម្ចាស់បានទទួលយកការលះបង់ ដែលព្រះអង្គបានធ្វើជំនួសយើង។
- **នេះជាអំណោយនៃសេចក្ដីសង្គ្រោះ** ដែលក្នុងនោះ យើងមិនសមនឹងទទួលការអត់ទោសបាប តែយើងអាចទទួលការអត់ទោសបាប និងសេចក្ដីសង្គ្រោះ ដោយព្រះគុណរបស់ព្រះអង្គ តាមរយៈសេចក្ដីជំនឿរបស់យើង គឺគ្មានមធ្យោបាយណាផ្សេងទៀតឡើយ។

តាមពិត ការអះអាងខាងលើនេះ គឺជាសេចក្ដីពិតជាមូលដ្ឋាន នៃដំណឹងល្អរបស់ព្រះយេស៊ូវ ជាសេចក្ដីពិតតែមួយគត់ ដែលនាំឲ្យអ្នកទទួលសេចក្ដីសង្គ្រោះ។ ព្រះទ្រង់នឹងជួយអ្នក ឲ្យអាចជម្នះបញ្ហាលំបាក ដែលអ្នកមាន នៅក្នុងការសម្រេចចិត្តទទួលបុណ្យជ្រមុជទឹក ទៅព្រះវិហារ និងរស់នៅជាគ្រីស្ទបរិស័ទ ខណៈពេលដែលអ្នកចាប់ផ្ដើមការធ្វើដំណើរជាមួយព្រះអង្គ។

អ្នកអាចសម្រេចចិត្តទទួលជឿព្រះយេស៊ូវ នៅពេលឥឡូវនេះបាន! អ្នកអាចអធិស្ឋានទទួលជឿព្រះអង្គ តាមលំនាំខាងក្រោមនេះ។ ពាក្យពេចន៍ខាងក្រោមនេះ គឺគ្រាន់តែជាលំនាំនៃការអធិស្ឋាន តែដែលសំខាន់បំផុតនោះ គឺអ្នកបានអធិស្ឋានចេញចិត្តរបស់អ្នក :

> *ព្រះអម្ចាស់យេស៊ូវអើយ ទូលបង្គំត្រូវការព្រះអង្គ។ សូមអរព្រះគុណព្រះអង្គ ដែលបានសុគតនៅលើឈើឆ្កាងជំនួសទូលបង្គំ។ ទូលបង្គំសូមបើកចិត្តទូលបង្គំ ទទួលព្រះអង្គធ្វើជាព្រះអង្គសង្គ្រោះ និងជាព្រះអម្ចាស់របស់ទូលបង្គំ។ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានអត់ទោសបាបឲ្យទូលបង្គំ ហើយប្រទានជីវិតអស់កល្បជានិច្ចដល់ទូលបង្គំ។ សូមព្រះអង្គយាងមកសោយរាជ្យ លើបល្ល័ង្កជីវិតទូលបង្គំ។ សូមកែច្នៃទូលបង្គំឲ្យទៅជាមនុស្សដែលព្រះអង្គសព្វព្រះហឫទ័យ អាម៉ែន។*

ព្រះជាម្ចាស់តែងតែស្ដាប់យើងជានិច្ច ដូចនេះ អ្វីដែលយើងត្រូវធ្វើ នោះគឺត្រូវនិយាយទៅកាន់ព្រះអង្គ គឺហាក់ដូចជាព្រះអង្គកំពុងតែនៅពីមុខយើង។ បើសិនជាអាច សូមឲ្យមិត្តភក្តិជាគ្រីស្ទបរិស័ទ អធិស្ឋានជាមួយអ្នក។






បើសិនជាលោកអ្នកចង់ស្វែងយល់បន្ថែមអំពីព្រះយេស៊ូវ និងអំពីការអ្វីដែលព្រះអង្គបានធ្វើសម្រាប់អ្នក សូមទាញយក ឬdownload សៀវភៅ រឿងនៃក្តីសង្ឃឹម តាមអាស័យដ្ឋាន :

https://khmer-odb.org/ds/story-of-hop/

**Scan the QR Code** to read it online, or contact us if you would like to receive a a print copy.

We invite you to also check out **odb.org** to view our other printed and digital resources.